# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីសិទ្ធិគ្រប់យ៉ាងរបស់ប្រជាពលរដ្ឋខ្មែរ តើអ្នកដឹកនាំខ្មែរបានអនុវត្តតាមធម្មនុញ្ញនៃអង្គការសហប្រជាជាតិនិងរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្នបានពេញលេញហើយឬនៅ ហើយព្រះពុទ្ធបានសំដែងដូចម្តេចដែរអំពីសិទ្ធិមនុស្សនេះ ?

website : www.hoksavann.org

ថ្ងៃទី១២ ធ្នូ ២០០៦

ថ្ងៃទី១០ធ្នូឆ្នាំ២០០៦កន្លងមកនេះ ប្រទេសក្នុងពិភពលោកបានធ្វើបុណ្យរំលឹកធម្មនុញ្ញនៃសិទ្ធិមនុស្ស ដែលអង្គការសហប្រជាជាតិបានប្រកាសជាសកលកាលពីថ្ងៃទី១០ឆ្នាំ១៩៤៨ ។ ក្នុងពេលនេះ សូមលើកយកតែសិទ្ធិបញ្ចេញយោបល់តាមរូបភាពផ្សេងៗ មកប្រៀបធៀបពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធព្រះបរមគ្រូ ។

ជនគ្រប់រូបមានសិទ្ធិសេរីភាពបញ្ចេញយោបល់ និងសំដែងមនោសញ្ចេតនារបស់ខ្លួនបានដោយសេរី ។ បានសេចក្តីថា អាចប្រើសិទ្ធិនេះដោយគ្មានការព្រួយបារម្ភ ។ សិទ្ធិសិក្សាស្រាវជ្រាវ សិទ្ធិទទួលនិងផ្សាយពត៌មាន ក៏មានន័យដូចគ្នា ។ សិទ្ធិបញ្ចេញមតិតាមសំដីនិយាយ តានការសរសេរ តាមរយៈការធ្វើកូដកម្មជាដើម ក៏មានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ។ នេះជាច្បាប់សកល ដើម្បីឲ្យមនុស្សគោរពសិទ្ធិគ្នា ជៀសវាងការបៀតបៀនគ្នា ។

ក្នុងរបបនេះ សិទ្ធិទាំងប៉ុន្មានដូចបានពោលមកខាងលើ ត្រូវបំបិទទាំងស្រុង ។ ប្រជាពលរដ្ឋទូទាំងប្រទេស ត្រូវតែដើរតាមមាគ៌ារបបកុម្មុយនិស្ត ដែលមានគណៈមជ្ឈិមបក្សជាអ្នកដឹកនាំ ។ សិទ្ធិបុគ្គលកម្មសិទ្ធិឯកជនត្រូវលុបបំបាត់ចោល ហើយកិច្ចការគ្រប់យ៉ាង មានកិច្ចការសង្គមកិច្ចជាដើម ត្រូវស្ថិតនៅលើសមូហភាព ។ របបកុម្មុយនិស្តខ្មែរពេលនេះ មានសភាពសាហាវនិងតឹងរ៉ឹងជាទីបំផុត ជាងកុម្មុយនិស្តសកលលោក ។ ផលវិបាកនៃរបបនេះ ពលរដ្ឋខ្មែរបានត្រូវស្លាប់រាប់លាននាក់ក្នុងរយៈកាលតែជាង៣ឆ្នាំប៉ុណ្ណោះ ។ គេឲ្យប្រជាពលរដ្ឋខ្មែរមានយោបល់ តែជាយោបល់ស្ថិតនៅក្នុងក្របខណ្ឌនៃមាគ៌ាបក្ស ។ ប្រជាពលរដ្ឋខ្មែរត្រូវតែធ្វើតាមបក្ស

ដាក់ទិស គ្មានសិទ្ធិជំទាស់ឡើយ ។ ប្រជាពលរដ្ឋប្រៀបដូចជាម៉ាស៊ីន ដែលមានចលនាដោយសារតែគេចុចគន្លឹះឲ្យដើរតែប៉ុណ្ណោះ ។ របបនេះយល់ថា ការឲ្យសិទ្ធិដល់បុគ្គលម្នាក់ៗ នឹងបើកឲ្យសក្តិភូមិនិងមូលធនរស់ឡើងវិញ ។ ត្រង់នេះផ្ទុយគ្នាពីរបបប្រជាធិបតេយ្យសេរី ដែលថាអំណាចគ្រប់យ៉ាងកើតចេញមកពីប្រជាពលរដ្ឋ ហើយថាសិទ្ធិមនុស្សជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ ។ ដូចនេះបញ្ជាក់ថា របបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) ជារបបផ្តាច់ការ រំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់បំផុត ដែលសហគមអន្តរជាតិនិងប្រជាពលរដ្ឋខ្មែរ សុំឲ្យមានការកាត់ទោសដើម្បីរកយុត្តិធម៌ជូនអ្នករងគ្រោះ ។

ក្រឡេកមកមើលធម្មនុញ្ញនៃរាជាណាចក្រកម្ពុជាបច្ចុប្បន្នត្រង់មាត្រា៣១ចែងថា ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ។ ត្រង់មាត្រាទី៣៧ចែងថា សិទ្ធិធ្វើកូដកម្ម និងបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខណ្ឌនៃច្បាប់ ។ មាត្រា៤១ចែងថា ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ល។ តាមការដកស្រង់នូវមាត្រាខ្លះនៃរដ្ឋធម្មនុញ្ញខ្មែរមកនេះបញ្ជាក់ថា ជារដ្ឋធម្មនុញ្ញនៃប្រទេសប្រជាធិបតេយ្យ គោរពសិទ្ធិមនុស្ស និងគោរពសិទ្ធិបញ្ចេញមតិរបស់ប្រជាពលរដ្ឋខ្មែរ ។ តើរាជរដ្ឋាភិបាលខ្មែរបច្ចុប្បន្ននេះ គោរពតាមមាត្រាទាំងនេះឬទេ ? យើងសង្កេតឃើញថា រាជរដ្ឋាភិបាលខ្មែរបានអនុញ្ញាតច្បាប់ ឲ្យសារព័ត៌មានចេញផ្សាយជាច្រើន ប៉ុន្តែមានបុគ្គលិកនៃសារព័ត៌មានខ្លះ បានត្រូវគេលួចបាញ់សម្លាប់ ចំពោះសារព័ត៌មានណាដែលសរសេរប្រឆាំងរដ្ឋាភិបាល ។ វិទ្យុនិងទូរទស្សន៍ទាំងអស់របស់រដ្ឋនិងរបស់ឯកជន ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល ។ ការផ្សាយវិទ្យុនិងទូរទស្សន៍របស់ឯកជន ពុំស្ថិតនៅភាពអព្យាក្រឹត្យនិងឯករាជ្យ ច្រើនផ្សាយលំអៀងទៅរករាជរដ្ឋាភិបាល ។ មានតែវិទ្យុសំបុកឃ្មុំមួយគត់ ដែលហ៊ានផ្សាយការពិតមិនលំអៀង ប៉ុន្តែក៏ប្រថុយប្រថានចំពោះគ្រោះថ្នាក់ដែរ ។ សិទ្ធិធ្វើកូដកម្មបាតុកម្ម ស្ទើរតែបិទទាំងស្រុង ។ ចាប់តាំងពីបាតុកម្មវាយទូតថៃមក ក្រសួងមហាផ្ទៃនិងសាលាក្រុងភ្នំពេញ មិនដែលអនុញ្ញាតច្បាប់ឲ្យធ្វើឡើយ ។ ប៉ុន្តែគួរឲ្យអស់សំណើចបាតុកម្មណាដែលគាំទ្ររដ្ឋាភិបាលនិងប្រឆាំងបក្សប្រឆាំង អាជ្ញាធរខ្មែរអនុញ្ញាតឲ្យធ្វើ ជាឧទាហរណ៍ដូចសាស្ត្រាចារ្យនៃមហាវិទ្យាល័យពីរបី ចងបដានៅមុខមហាវិទ្យាល័យប្រឆាំងលោកសម-រង្ស៊ីជាដើម ។ សុំច្បាប់មិនឲ្យ បើប្រជាពលរដ្ឋណាហ៊ានធ្វើ ត្រូវប៉ូលិសបង្ក្រាបដោយដំបងឆក់ ដោយចោទថាជាបាតុកម្មគ្មានច្បាប់ ។ ការបញ្ចេញមតិក៏ត្រូវគេចោទថា បរិហារកេរ្តិ៍ ដូចសកម្មជនសិទ្ធិមនុស្ស សកម្មជនព្រំដែន ដែលបញ្ចេញមតិការពារទឹកដីរបស់ខ្លួន ត្រូវគេចោទចាប់ដាក់គុកព្រៃស ។ គួរឲ្យអស់សំណើចមួយទៀត សកម្មជនសិទ្ធីមនុស្សក្នុងពេលថ្មីៗនេះ បំរុងបញ្ចេញមតិ

តាមការបង្ហោះខ្លែង ក៏គ្មានច្បាប់ធ្វើបានដែរ ដូចជាជ្រុលពេកហើយរាជរដ្ឋាភិបាលខ្មែរ ។ ចំណែកប៉ូលិសវិញ មានសមត្ថភាពបង្ក្រាប ប៉ុន្តែគ្មានសមត្ថភាពការពារ ។ តាមការទាញយកសកម្មភាពរបស់រាជរដ្ឋាភិបាលខ្មែរ មកបញ្ជាក់ខ្លះៗប៉ុណ្ណោះបញ្ជាក់ថា រាជរដ្ឋាភិបាលខ្មែរមិនទាន់គោរពសិទ្ធិប្រជាពលរដ្ឋខ្មែរ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្ន ឲ្យបានបោញលេញនៅឡើយទេ ។

ព្រះពុទ្ធជាញាណទស្សនវិទូវិញ ព្រះអង្គបានដាក់មេរៀនឲ្យមនុស្សចេះចែករំលែកសេចក្ដីសុខឲ្យដល់គ្នាដោយសម្ភារៈគឺ អាមិសទាន ដោយការផ្ដល់ចំណេះចេះដឹងគំនិតបញ្ញា គឺធម្មទាន ។ ព្រះអង្គបានដាស់តឿនថា ត្រូវនាំគ្នាខំហាត់ខំរៀនខំសិក្សាខំអនុវត្តឲ្យបាន នូវការគោរពសិទ្ធិគ្នា ជៀសចាងការបៀតបៀន ដោយការរក្សាសីល ។ លើសពីនេះទៅទៀត ព្រះអង្គបានរំលឹកថា ចិត្តជាធាតុសំខាន់របស់អំពើ ដូច្នេះត្រូវសំអាតចិត្តឲ្យស្អាតបរិសុទ្ធ សូម្បីតែគិតថាបៀតបៀន ក៏មិនត្រូវគិតដែរ ។ ព្រះអង្គគោរពយោបល់និងការសំរេចចិត្តរបស់អ្នកដទៃ ដូចព្រះអង្គបញ្ជាក់ថា តថាគតសំដែងធម៌ដល់អ្នក មុននឹងជឿចូរអ្នកពិចារណាឲ្យម៉ត់ចត់ ហើយអ្នកមានសិទ្ធិសំរេចចិត្តជឿឬមិនជឿតថាគតបាន ។ មួយទៀត ការគោរព ការសំរេចចិត្តរបស់អង្គប្រជុំជាឯកច្ឆន្ទ ឬភាគច្រើន មាននិយាយក្នុងសង្ឃកម្ម គឺកិច្ចការរបស់ព្រះសង្ឃមានលក្ខណៈដូចប្រជាធិបតេយ្យក្នុងផ្លូវអាណាចក្រ ។